# ការប៉ាន់ប្រមាណបុគ្គលដែលមានជំងឺផ្លូវចិត្ត

## Assess Person with Mental Illness

*Present by Keo Somony PhD student.*

# គោលបំណងនៃមេរៀន Objective of the lesson

១.ពន្យល់ពីលក្ខណៈសម្បត្តិដែលអាចធ្វើជាអ្នកពិនិត្យជំងឺផ្លូវចិត្ត

២.រៀបរាប់ពីរបៀបសម្គាល់មនុស្សដែលមានជំងឺផ្លូវចិត្ត

៣.រៀបរាប់ពីសំណួរដែលគប្បីត្រូវសួរទៅមនុស្សដែលមានជំងឺផ្លូវចិត្ត

៤.រៀបរាប់ពីកម្រងសំណួរ និង រោគសញ្ញា ដើម្បីកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្ត

# គោលបំណងនៃមេរៀន (ត)

៥. រៀបរាប់ពីសំណួរដែលត្រូវសួរក្នុងពេលសំភាសន៍
៦. រៀបរាប់ពីការសំភាសន៍
៧. រៀបរាប់ពីស្ថានភាពពិសេសក្នុងការប៉ាន់ប្រមាណ

# វត្ថុបំណងទី១

ពន្យល់ពីលក្ខណៈសម្បត្តិដែលអាចធ្វើជាអ្នកពិនិត្យជំងឺផ្លូវចិត្ត



# សំណួរ

តើយើងអាចពិនិត្យមនុស្សម្នាក់ដែលមានជំងឺផ្លូវចិត្តបានដែរឬទេ?

# អាចពិនិត្យមនុស្សដែលមានជំងឺផ្លូវចិត្តបានដោយៈ

- ការប៉ាន់ប្រមាណអ្នកជំងឺផ្លូវចិត្តវាមិនចាំបាច់ធ្វើដោយអ្នកឯកទេសទេ
- ត្រូវមានក្តីករុណ ការអាណិតអាសូរ

# អ្នកអាចពិនិត្យមនុស្សដែលមានជំងឺផ្លូវចិត្តបាន (ត)

- ត្រូវមានជំនាញក្នុងការស្តាប់ដោយប្រុងប្រយ័ត្ន



# អារម្មណ៍បុគ្គលិកសុខាភិបាលពេលពិនិត្យអ្នកជំងឺផ្លូវចិត្ត

- ភ័យខ្លាចអ្នកជំងឺវាយដុំមកលើខ្លួន
- ខ្ពើមរអើមអ្នកជំងឺដោយគាត់គ្នានអនាម័យ
- នឿយណាយដោយចំណាយពេលយូរ

# អារម្មណ៍បុគ្គលិកសុខាភិបាលពេលពិនិត្យអ្នកជំងឺផ្លូវចិត្ត (ត)

- មើលទៅគួរអោយអស់សំណើច ចំពោះ អាកប្បកិរិយាប្លែកៗរបស់អ្នកជំងឺ
- ខឹងដោយសារខាតពេល ពីព្រោះពិនិត្យទៅរកមិនឃើញមានជំងឺអ្វីមួយពិតប្រាកដ

# អារម្មណ៍បុគ្គលិកសុខាភិបាលពេលពិនិត្យអ្នកជំងឺផ្លូវចិត្ត(ត)

- ជាការសំខាន់អ្នកពិនិត្យត្រូវមានពេលគ្រប់គ្រាន់ជាមួយអ្នកជំងឺ
- វាធ្វើអោយមានការលំបាកដល់អ្នកធ្វើការប៉ាន់ប្រមាណនៅវិញ
- អាចធ្វើអោយប៉ះពាល់ភាពសុខស្រួលរបស់អ្នកជំងឺ
- អ្នកជំងឺ នឹងមិនចង់និយាយពីអារម្មណ៍របស់ខ្លួន

# តើអ្នកមានពេលពិនិត្យអ្នកជំងឺផ្លូវចិត្តដែរឬទេ?

- អាចសន្សំពេលទៅថ្ងៃក្រោយ
- បុគ្គលិកសុខាភិបាលមួយចំនួនពុំដឹងថាគាត់មានជំងឺផ្លូវចិត្តទេ
- ផ្តល់ថ្នាំតាមរោគសញ្ញាដែលអ្នកជំងឺបានត្អូញត្អែរតែប៉ុណ្ណោះ
- អ្នកជំងឺនឹងវិលមកជួបអ្នកម្តងទៀត

# វត្ថុបំណងទី២

រៀបរាប់របៀបសម្គាល់មនុស្សដែលមានជំងឺផ្លូវចិត្ត ?

# តើអ្នកណាដែលមានជំងឺផ្លូវចិត្ត?

- វាកើតមានគ្រប់គ្នា
- មនុស្សឈឺជំងឺផ្លូវចិត្ត មានអាកប្បកិរិយា និងការនិយាយស្ដីមិនខុសពីអ្នកជំងឺរាងកាយទេ
- អ្នកជំនាញត្រូវប្រើសំណួរមួយចំនួនដើម្បីកំណត់ថាបុគ្គលនោះមានជំងឺផ្លូវចិត្ត

# តើអ្នកណាដែលមានជំងឺផ្លូវចិត្ត?

មានវិធីសាស្ត្រពីរយ៉ាងក្នុងការវិភាគអ្នកជំងឺនៅកន្លែងគ្លីនិក៖

១.ការសង្កេតទៅលើប្រភេទជំងឺមួយចំនួន ដែលជាការស្តែងឡើង ជាសញ្ញាពិតប្រាកដនៃជំងឺផ្លូវចិត្ត (តារាង២.១)

២.សួរនូវសំណួរមួយចំនួន ដែលជួយតម្រង់ទៅរកជំងឺផ្លូវចិត្ត ដែលកើតមានញឹកញាប់(តារាង២.២)

# (តារាង២.១) លក្ខណៈបង្ហាញមួយចំនួនដែលគិតថា ជាជំងឺផ្លូវចិត្ត

- កាលណាបុគ្គលត្អូញត្អែរពីបញ្ហាផ្លូវចិត្តត្រង់ៗដូចជាការ ធ្លាក់ទឹកចិត្ត ឬបញ្ហាញៀនស្រា
- កាលណាបុគ្គលមានការសង្ស័យទាក់ទងនឹង អបិយជំនឿនានាដែលមិនសមហេតុផល
- កាលណាបុគ្គលមានមូលហេតុជាកលាក់នៃជំងឺផ្លូវចិត្តដូចជាការផឹកស្រាឬមានអំពើហឹង្សាក្នុងគ្រួសារ

# (តារាង២.១)លក្ខណៈបង្ហាញមួយចំនួនដែលគិតថាជាជំងឺផ្លូវចិត្ត (ត)

- កាលណាបុគ្គលនោះមានទំនាក់ទំនងមិនល្អរវាងប្ដីប្រពន្ធ និងមានបញ្ហាផ្លូវភេទ
- កាលណាបុគ្គលនោះ មានបញ្ហាក្នុងជីវិតដូចជាគ្មានការងារធ្វើ ឬ ការស្លាប់មិត្តជិតស្និទ្ធ

# (តារាង២.១) លក្ខណៈបង្ហាញមួយចំនួន ដែលគិតថាជាជំងឺផ្លូវចិត្ត (ត)

- មានការត្អូញត្អែរពីបញ្ហារាងកាយជាច្រើន (លើសពី៣)ដែលមិនសមនឹងជំងឺរាងកាយណាមួយ
- កាលណាបុគ្គលនោះ ឬគ្រួសារធ្លាប់មានជំងឺផ្លូវចិត្ត

# Sexual Response Cycle



# (តារាង២.២) សំណួរល្អៗ Golden Questions សម្រាប់សង្កេតរកអ្នកជំងឺផ្លូវចិត្តនៅកន្លែងពិនិត្យជំងឺទូទៅ

- តើអ្នកមានបញ្ហាដេកមិនលក់នៅពេលយប់ដែរឬទេ?
- តើអ្នកមានអារម្មណ៍ថាបាត់បង់ការចាប់អារម្មណ៍ចំពោះការងារឬសកម្មភាពប្រចាំថ្ងៃដែរឬទេ?
- តើថ្មីៗនេះអ្នកមានអារម្មណ៍ក្រៀមក្រំឬមិនសប្បាយចិត្តមែនឬទេ?

# (តារាង២.២)សំណួរល្អៗ Golden Questions សម្រាប់ សង្កេតរកអ្នកជំងឺផ្លូវចិត្តនៅកន្លែងពិនិត្យជំងឺទូទៅ(ត)

- តើអ្នកមានអារម្មណ៍ភ័យខ្លាចចំពោះអ្វីៗគ្រប់រឿងដែរឬទេ?
- តើថ្មីៗនេះអ្នកព្រួយចិត្តអំពីការផឹកស្រាច្រើនដែរឬទេ?
- តើថ្មីៗនេះអ្នកបានចំណាយប្រាក់កាស់និងពេលវេលាអស់ប៉ុន្មានទៅលើស្រា?

# សំណួរល្អ(មាស) Golden Questions (cont)

ប្រសិនជាចំលើយនីមួយៗ បាទ ឬ ចាស នោះ ត្រូវសួរលំអិតបន្ថែមដើម្បីកំណត់រករោគវិនិច្ឆ័យ

# វគ្គបំណងទី៣

រៀបរាប់ពីសំណួរដែលត្រូវសួរ
មនុស្សដែលមានជំងឺផ្លូវចិត្ត

# សំណួរ

តើសំណួរអ្វីខ្លះដែលត្រូវសួរទៅមនុស្សដែលមានជំងឺផ្លូវចិត្ត?



# ព័ត៌មានពប្រភេទ ដែលត្រូវសួរដើម្បីកំណត់បញ្ហា

ប្រភេទព័ត៌មានទី១ ៖

- អាយុ
- អាស័យដ្ឋានរបស់ក្រុមគ្រួសារ
- ការងាររបស់មុនស្សដែលមកពិគ្រោះជាមួយអ្នក

# ព័ត៌មាន៣ប្រភេទដែលត្រូវសួរ ដើម្បីកំណត់បញ្ហា(ត)

ប្រភេទព័ត៌មានទី២ ៖

អ្នកជំងឺផ្ទាល់ ៖ គួរចាប់ផ្តើមសួរគាត់ដោយការរកឃើញរោគសញ្ញា

ឧទាហរណ៍៖ តើរោគសញ្ញានោះចាប់ផ្តើមតាំងពីពេលណា?តើវាប៉ះពាល់ដល់ជីវិតរស់នៅរបស់អ្នកយ៉ាងដូចម្តេច?

- Information about the illness itself should begin with finding out about the symptoms ,for example how long they have been present and how long they affect the person’s life.

# ព័ត៌មានពប្រភេទដែលត្រូវសួរដើម្បីកំណត់បញ្ហា(ត)

ប្រភេទព័ត៌មានទី៣ ៖

សួរពីស្ថានភាពសង្គមរបស់អ្នកជំងឺ រួមបញ្ចូល អ្នកណាដែលកំពុងរស់នៅជាមួយ ហើយអ្នកណាជាមនុស្សសំខាន់ដែលគាំទ្រនៅក្នុងសង្គមគ្រួសារនោះ ។

then you should ask about person’s social situation. this should include who the person living with and who are the main source of social support.

# ព័ត៌មានផ្សេងៗទៀតដែលត្រូវ ប្រមូលកត់ត្រា

- តើបុគ្គលធ្លាប់មានជំងឺផ្លូវចិត្តដែរឬទេ?បើធ្លាប់សួរវេជ្ជបញ្ជានិងកំណត់ហេតុនៃការព្យាបាលពីមុន។
- ប្រវត្តិពាក់ព័ន្ធនឹងបញ្ហាផ្លូវចិត្ត ដូចជាធ្លាប់របួសក្បាល
- ធ្លាប់មានព្រឹត្តិការណ៍ធំៗក្នុងជីវិត
- អ្នកផ្គត់ផ្គង់

# ព័ត៌មានផ្សេងៗដែលត្រូវប្រមូល (ត)

- ភេទ
- អាយុ
- មុខរបរ
- ស្ថានភាពអាពាហ៍ពិពាហ៍

# ព័ត៌មានដែលត្រូវប្រមូលចំពោះបុគ្គលដែលសង្ស័យថា មានជំងឺផ្លូវចិត្ត

## ប្រវត្តិនៃការត្អូញត្អែរនាពេលថ្មីៗ៖

- តើបញ្ហានោះកើតមានយ៉ាងដូចម្តេច?
- តាំងពីពេលណាមក?
- ហេតុអ្វីបានជាវាកើតឡើង?
- តើវាធ្ងន់ធ្ងរទេ?
- តើបុគ្គលយល់យ៉ាងណាអំពីជំងឺរបស់គាត់

# ព័ត៌មានដែលត្រូវប្រមូលចំពោះបុគ្គលដែលសង្ស័យថា មានជំងឺផ្លូវចិត្ត

What to ask a person with a probable mental illness

ទម្រង់ (Form) ជាគម្រូមួយនៃការសំភាសន៍ ត្រូវបានគេប្រើសម្រាប់បំពេញព័ត៌មានអ្នកជំងឺដែលជាលទ្ធផលនៃការពិនិត្យជំងឺ

A standard form of interview can be used for people who, as a result of the screening process

# វគ្គបំណងទី៤

រៀបរាប់អំពីកម្រងសំណួរនិងរោគសញ្ញាដើម្បីកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្ត

# កម្រងសំណួរ Questionnaire

មានកម្រងសំណួរពាប្រភេទដែល

គេប្រើ ដើម្បីកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្ត

# កម្រងសំណួរពាក្យប្រភេទ

១.ការកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តដែលកើតមានញឹកញាប់

២.ការកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តធ្ងន់ធ្ងរ

៣.កំណត់រោគវិនិច្ឆ័យការញៀនសុរាឬគ្រឿងញៀន

# ១.កំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តដែលកើតញឹកញាប់

បុគ្គលត្រូវមានរោគសញ្ញា(សំខាន់មួយ)ក្នុងចំណោមរោគសញ្ញា(សំខាន់បី)ដូចខាងក្រោម ក្នុងរយៈពេលយ៉ាងតិច២អាទិត្យ៖

- មានអារម្មណ៍ក្រៀមក្រំ
- គ្មានការចាប់អារម្មណ៍សកម្មភាពប្រចាំថ្ងៃ
- មានអារម្មណ៍ តានតឹងជ្រួលច្របល់ ឬព្រួយចិត្តច្រើន

# រោគសញ្ញាសំខាន់បីនេះ ទាក់ទងនឹង

- ជំងឺធ្លាក់ទឹកចិត្ត
- ជំងឺថប់បារម្ភ

ដែលពួកវាច្រើនកើតមានញឹកញាប់



# កំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តដែលកើតញឹកញាប់(ត)

នៅពេលមានរោគសញ្ញាដូចខាងលើ ត្រូវបន្តសួររករោគសញ្ញាបន្ថែមទៀត៖

- ការរំខានការដេក(ប្រែប្រួលដំណេក)
- ហត់នឿយ អស់កំលាំង
- បាត់បង់រសជាតិអាហារ(មិនសូវឃ្លានអាហារ)
- ពិបាកក្នុងការផ្តង់អារម្មណ៍

# ការរំខានការដេក(ប្រែប្រួលដំណេក)

- Difficulty in falling asleep
- Midnight wake up
- Early morning wake up



# រោគសញ្ញាត្រូវរកបន្តទៀត

## មានគំនិតចង់ធ្វើអត្តឃាត

5:31 LTE

គួរឲ្យសោកស្តាយដែលបងប្រុសម្នាក់រត់កង់បីបានធ្វើ
អត្តឃាតដោយចងករសម្លាញ់ខ្លួនជាមួយកង់បីរបស់គាត់
ក្រោយពីបានស៊ើបសួរពត៌មានពីប្រពន្ធបានប្រាប់ថា
មូលហេតុ មានជំងឺប្រចាំកាយផង មានជាប់បំណុលគេផង
ដែលបង្ខំចិត្តធ្វើបែបនេះ ! សូមផ្ញើសារដល់បងប្អូនដែល
ប្រកបរបររកស៊ីដូចគ្នា មេត្តាគិតអោយបានល្អិតល្អន់ បញ្ហា
មានគ្រប់គ្នា យើងទៅបានសុខហើយ តែបន្សល់បន្ទុក
កាន់តែធ្ងន់ធ្ងរដល់អ្នកដែលរស់នៅគឺប្រពន្ធនិងកូន
01/05/2025 ។ល។



# រោគសញ្ញាត្រូវរកបន្តទៀត (ត)

- ញ័រទ្រូង(បេះដូងដើរញាប់)វិលមុខ
- ឈឺចាប់សព្វរាងកាយ

# ២.ការកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តធ្ងន់ធ្ងរ

បុគ្គលត្រូវមានសញ្ញាយ៉ាងតិច២ក្នុងចំណោម
រោគសញ្ញាដូចខាងក្រោម៖

## ជឿទៅលើអ្វីដែលមិនមានពិត៖

គាត់ជឿថាគំនិតរបស់គាត់ត្រូវបានគ្រប់គ្រងដោយកំលាំងខាងក្រៅ ឬជឿថាមានមនុស្សកំពុងតែព្យាយាមដាក់ថ្នាំបំពុលគាត់ (Delusion)

# ការកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តធ្ងន់ធ្ងរ(ត)

- ស្តាប់ឮឬមើលឃើញអ្វីដែលអ្នកផ្សេងស្តាប់មិនឮមើលមិនឃើញ(Hallucination)ជារឿយៗមានការភ័យខ្លាច
- ជ្រួលច្របល់និងរសាប់រសល់ឬដកខ្លួនចេញពីគេ
- បាត់បង់ការចាប់អារម្មណ៍ឬគ្មានអារម្មណ៍(Empty mood)

# ការកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តធ្ងន់ធ្ងរ(ត)

រោគសញ្ញាកើតក្រោមមួយខែ

→ Acute psychosis

រោគសញ្ញាលើសពីមួយខែ

→ Schizophrenia

# Normal and Abnormal brain in Schizophrenia



# ការកំណត់រោគវិនិច្ឆ័យជំងឺផ្លូវចិត្តធ្ងន់ធ្ងរ(ត)

ប្រសិនអ្នកជំងឺធ្លាប់មានប្រវត្តិជំងឺវិកលចរិតហើយ ទំនងជាបានជាសះស្បើយ នោះរោគវិនិច្ឆ័យអាចជា

Bipolar Disorder

ដំណាក់កាលដែលអារម្មណ៍អ្នកជំងឺឡើងខ្លាំង Manic Episode គេអាចកំណត់រោគវិនិច្ឆ័យជំងឺទៅតាមរោគសញ្ញាដូចខាងក្រោម:

# ដំណាក់កាលដែលអារម្មណ៍អ្នកជំងឺឡើងខ្លាំង Manic Episode

- កើនឡើងល្បឿននៃការនិយាយ Increase speed of talking
- អារម្មណ៍មួម៉ៅ ឆាប់មានកំហឹង Irritable mood (getting angry easily)
- ឡេះឡាស់ Agitation
- មានគំនិតយល់ថាអ្វីៗបែបអស្ចារ្យ(ហួសពីការពិត) Grand Ideas ( out of keeping with reality)

# Manic Depressive Disorder
# ( called bipolar disorder )

ជម្ងឺក្រោមបង្ហាញ Manic Depressive disorder



# Manic Depressive Disorder



# ៣.កំណត់រោគវិនិច្ឆ័យការញៀនសុរា ឬគ្រឿងញៀន

បុគ្គលត្រូវមានរោគសញ្ញាយ៉ាងតិច០២(ចំណោម៩) រយៈពេល**យ៉ាងតិចជាងមួយខែ** ដូចខាងក្រោម ៖

១.ផឹកស្រា ឬប្រើថ្នាំញៀន នាំអោយមានបញ្ហា បាត់បង់ការងារ ឬមានបញ្ហាសុខភាព ដូចជា ស្បែកឡើងលឿងឬគ្រោះថ្នាក់ផ្សេងៗ

# ការកំណត់រោគវិនិច្ឆ័យការញៀនសុរា ឬគ្រឿងញៀន(ត)

២.ពិបាកគ្រប់គ្រងការប្រើប្រាស់ស្រាឬគ្រឿងញៀនបើទោះជាកើតមានបញ្ហាដោយសារការប្រើប្រាស់សារធាតុទាំងនោះក្ដី

៣.ប្រើប្រាស់សុរាឬគ្រឿងញៀនជាបន្តបន្ទាប់ក្នុងមួយ ថ្ងៃ

# ការកំណត់រោគវិនិច្ឆ័យការញៀនសុរាឬគ្រឿងញៀន(ត)

៤.មានអារម្មណ៍ថាឈឺ ធ្វើអ្វីមិនកើត បើមិនបាន ប្រើប្រាស់សុរា ឬគ្រឿងញៀនទេ

៥.ប្រើប្រាស់សុរាឬគ្រឿងញៀន កាន់តែកើនឡើងជា លំដាប់



# វគ្គបំណងទី៥

## រៀបរាប់ពីអ្វីត្រូវសួរពេលសំភាសន៍?



# តើអ្វីត្រូវកត់សម្គាល់ពេលសំភាសន៍?

ក្នុងពេលសំភាសន៍អ្នកត្រូវកត់សម្គាល់ចំណុចដូចខាងក្រោម:

- ទីកម្មុខ៖ក្រៀមក្រំ ឬ ភ័យខ្លាច វាមានទំនាក់ទំនងនឹងជំងឺធ្លាក់ទឹកចិត្ត និង Schizophrenia
- មានភាពរសាប់រសល់៖អង្គុយមួយកន្លែងមិនសុខ (ទាក់ទងនឹងជំងឺវិកលចរិត ធ្លាក់ទឹកចិត្ត ញៀនស្រាឬគ្រឿងញៀន ឬ ឥទ្ធិពលមិនល្អរបស់ថ្នាំព្យាបាលជំងឺផ្លូវចិត្តខ្លះ

# តើអ្វីត្រូវកត់សម្គាល់ពេលសំភាសន៍(ត)?

- មានចលនាចម្លែក ជាប់ទាក់ទងនឹងជំងឺ Schizophrenia ឬឥទ្ធិពលធ្វើទុក្ខរបស់ថ្នាំជំងឺផ្លូវចិត្តខ្លះ៖ Strange movements ( Associated with Schizophrenia and as a side-effect of some psychiatric medications

# តើអ្វីត្រូវកត់សម្គាល់ពេលសំភាសន៍(ត)?

- ឆ្លើយមិនត្រូវចំលើយ Irrelevant Answer ជាប់ទាក់ទងនឹងជំងឺវិកលចរិត
- និយាយយ៉ាងញាប់ A very fast rate of talking ជាប់ទាក់ទងនឹងជំងឺវិកលចរិត ពិសេសជំងឺ (Mania)

# តើអ្វីត្រូវកត់សម្គាល់ពេលសំភាសន៍(ត)?

- និយាយយ៉ាងយឺត ដាប់ទាក់ទង នឹងជំងឺផ្លាក់ទឹកចិត្ត ឥទ្ធិពលមិនល្អរបស់ថ្នាំព្យាបាលជំងឺផ្លូវចិត្តខ្លះ និង Schizophrenia
- អនាម័យទូទៅ និងការថែទាំខ្លួនមិនបានល្អដាប់ទាក់ទងនឹងជំងឺធ្លាក់ទឹកចិត្ត ការញៀនស្រា ឬគ្រឿងញៀន និងជំងឺ ស្កីហ្សូប្រេនៀ Schizophrenia

# អនាម័យទូទៅ និងការថែទាំខ្លួនមិនបានល្អជាប់ទាក់ទងនឹង ការញៀនស្រា ថ្នាំញៀន និងជំងឺ ស្គីហ្សូប្រេនៀ



# វគ្គបំណងទី៦

រៀបរាប់ពីរបៀបធ្វើ
បទសំភាសន៍?

# សំណួរ

## តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច?



# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច?

- ស្វាគមន៍អ្នកជំងឺនិងគ្រួសារដែលមកជាមួយ
- រកកន្លែងងាយស្រួល ក្នុងការ សំភាសន៍

- Greeting the patient and their relatives
- Find out place which suitable for interviewing

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

ណែនាំខ្លួនអោយអ្នកជំងឺស្គាល់អ្នក វិជ្ជាជីវៈរបស់អ្នក និងនិយាយទៅកាន់អ្នកជំងឺថា អ្នកនឹងនិយាយពីបញ្ហាសុខភាពបច្ចុប្បន្ន របស់គាត់

introduce yourself to the person and clearly state your professional role and say that you wish to talk about the person’s recent health.

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្ដេច(ត)?

ត្រូវបង្កើតទំនាក់ជាមួយអ្នកជំងឺដោយចាប់ផ្ដើមពីប្រធានបទទូទៅ

To establish rapport you can begin interview with general subject

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

បង្ហាញការអាណិតអាសូរចំពោះអ្នកជំងឺមានន័យថាដោយដាក់អារម្មណ៍របស់អ្នកនៅក្នុងអារម្មណ៍អ្នកជំងឺ ។

Empathy simply mean imaging what it must feel like to be in another person’s place.

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

មិនត្រូវប្រញាប់ប្រញាល់ដោយការមើលនាឡិកាញឹកញាប់ពេកទេ

–Do not hurry by frequently watching your watch.

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

- ផ្តល់ឧកាសអោយអ្នកជំងឺនិយាយដោយគ្មានគ្រួសារនៅក្បែរ
- កុំគិតថាអ្នកជំងឺជាមនុស្សមិនអាចទុកចិត្តបាន ដោយគាត់កំពុងមានជំងឺផ្លូវចិត្ត
- Give the patient a chance to talk without relation present.
- Never consider people “ unreliable” simply they suffer from a mental illness.

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

- ព្យាយាមនិយាយទៅកាន់ក្រុមគ្រួសារផងដែរ
  Try to speak to the relative as well.
- អ្នកជំងឺខ្លះគេបដិសេធពីជំងឺរបស់ខ្លួនឯង
  Some people with a mental illness may deny they have problem.

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

- សំឡឹងទៅអ្នកជំងឺ កំឡុងពេលសំភាសន៍

  **Look at the patient during the interview**

- ភ្នែកទល់ភ្នែក **Keep eye contact**
  - បែបនេះធ្វើអោយអ្នកជំងឺគិតថាអ្នកចាប់អារម្មណ៍ពីបញ្ហារបស់គាត់
  - **Can help make people feel confident that a health worker is interested in what they are saying**

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?
# How to conduct interview (cont)

- រក្សាភាពដាច់ដោយលែករបស់អ្នកជំងឺវាមិនអាចធ្វើបានទេប្រសិនជាមានអ្នកជំងឺរង់ចាំច្រើន។
- ស្នើអ្នកជំងឺរង់ចាំចំពោះការពិភាក្សាពីបញ្ហាផ្ទាល់ខ្លួនរហូតដល់អស់អ្នកជំងឺ

- Try to ensure privacy this may be impossible in crowded clinic.
- Ask patient to wait till the clinic less crowded.

# តើអ្នកត្រូវធ្វើបទសំភាសន៍ដូចម្តេច(ត)?

- កត់ត្រានូវព័ត៌មាន ពិសេសរោគសញ្ញា សំខាន់ៗ រោគវិនិច្ឆ័យពេលបច្ចុប្បន្ន ព័ត៌មាន សំខាន់ៗដែលអ្នកជំងឺកំពុងមាន ដូចជាវិបត្តិអាពាហ៍ពិពាហ៍ប្រសិនជាមាន។

**Record key information especially the main symptoms, current diagnosis and important information, such as the present of any marital problem.**

# វគ្គបំណងទី៧

រៀបរាប់ពីស្ថានភាពពិសេសក្នុងការប៉ាន់ប្រមាណ

# ស្ថានភាពពិសេសក្នុងការប៉ាន់ប្រមាណ

- ការប៉ាន់ប្រមាណអ្នកជំងឺដែលមិនព្រមនិយាយ
- ការប៉ាន់ប្រមាណបញ្ហារាងកាយបុគ្គលដែលមានជំងឺផ្លូវចិត្ត
- ការប៉ាន់ប្រមាណបុគ្គលម្នាក់តាមទូរស័ព្ទ
- ការប៉ាន់ប្រមាណបុគ្គលដែលមានគ្រួសារនៅក្បែរ

# ការប៉ាន់ប្រមាណអ្នកជំងឺដែលមិនព្រមនិយាយ

- អ្នកជំងឺដែលមិនព្រមនិយាយអាចបណ្តាលពី៖

  - គេនាំគាត់មកមន្ទីរពេទ្យ
  - អ្នកជំងឺបារម្ភថា គេនឹងមានឈ្មោះថាជាអ្នកជំងឺផ្លូវចិត្ត
- អ្នកជំងឺមានការសង្ស័យពីគោលបំណងនៃការជួយ

# ការប៉ាន់ប្រមាណអ្នកជំងឺដែលមិនព្រមនិយាយ (ត)

- ក្នុងករណីបែបនេះ ត្រូវចំណាយពេលវេលាអោយបានច្រើនជាមួយអ្នកជំងឺ។ប្រសិន
- ប្រសិនជាអាច ស្នើអោយបងប្អូនស្ថិតនៅឆ្ងាយពីការសន្ទនា
- មិនគម្រាមអ្នកជំងឺដោយនិយាយថាមិនមានពេលគ្រប់គ្រាន់ទេ

# ការប៉ាន់ប្រមាណអ្នកជំងឺដែលមិនព្រមនិយាយ (៣)

- គប្បីនិយាយទៅកាន់អ្នកជំងឺថាអ្នកចាប់អារម្មណ៍ពីបញ្ហារបស់គាត់
- ប្រសិនអ្នករវល់នឹងការងារអ្វីមួយ អ្នកត្រូវប្រាប់គាត់ថា អ្នកនឹងវិលមកជួបគាត់វិញនៅពេលក្រោយ ដើម្បីពិភាក្សាអ្វីដែលគាត់ចង់និយាយបន្ត

# ការប៉ាន់ប្រមាណបញ្ហារាងកាយបុគ្គលដែលមានជំងឺផ្លូវចិត្ត

- បុគ្គលដែលធ្លាប់មានបញ្ហាផ្លូវចិត្តស្រាប់តែពេលមកជួបជាលើកទី២ គាត់មានបញ្ហាថ្មីមួយទៀត
  ដូចជា ឈឺក្បាល
- ជារឿយៗបុគ្គលិកសុខាភិបាលនឹងសន្និដ្ឋានថាការត្អូញត្អែរគ្រាន់តែជារោគសញ្ញាថ្មីមួយទៀតនៃជំងឺផ្លូវចិត្តតែប៉ុណ្ណោះ
- ការគិតបែបនេះ ជាការមើលរំលងទៅលើបញ្ហារាងកាយរបស់អ្នកជំងឺ

# ការប៉ាន់ប្រមាណបញ្ហារាងកាយបុគ្គលដែលមានជំងឺផ្លូវចិត្ត (ត)

- វាជាការចាំបាច់ដែលអ្នកត្រូវយកចិត្តទុកដាក់ដល់សុខភាពរាងកាយរបស់អ្នកជំងឺផ្លូវចិត្តផងដែរ
- អ្នកគួរចាំថា អ្នកជំងឺផ្លូវចិត្ត អាចមិនយកចិត្តទុកដាក់ដល់សុខភាពរាងកាយរបស់ខ្លួនទេ

# ប្រសិនចាំបាច់អ្នកគប្បីពិនិត្យរកមើលបញ្ហារាងកាយបុគ្គលទាក់ទងនឹង:

- ការប្រើប្រាស់សុរា ឬគ្រឿងញៀន
- ស្រ្តីដែលរងនូវអំពើហឹង្សាឬ ការចាប់រំលោភ
- ភាពច្របូកច្របល់ និងច្រួលច្រាលជារឿយៗ បណ្តាលពីបញ្ហារាងកាយ
- អាកប្បកិរិយាខុសប្រក្រតីចំពោះមនុស្សចាស់



# ការប៉ាន់ប្រមាណបុគ្គលម្នាក់តាមទូរស័ព្ទ

- បុគ្គលមនុស្សមួយចំនួនអាចទូរស័ព្ទមកដើម្បីសុំយោបល់
- ធ្វើអោយចំណេញពេលសម្រាប់អ្នកនិងអ្នកទូរស័ព្ទមក
- អ្នកទូរស័ព្ទអាចមានបញ្ហាផ្លូវចិត្តដូចជា៖

# ការប៉ាន់ប្រមាណបុគ្គលម្នាក់តាមទូរស័ព្ទ(ត)

- មនុស្សដែលចង់ស្លាប់
- ក្មេងដែលត្រូវការអោយជួយ
- បុគ្គលដែលស្រវឹងនិងវង្វេងវង្វាន់
- បុគ្គលមានកំហឹងនិងបង្កទុក្ខទោស

# ការប៉ាន់ប្រមាណបុគ្គលម្នាក់តាមទូរស័ព្ទ(ត)

- អ្នកមិនត្រូវផ្តល់យោបល់ឬការលើកបញ្ជាក់បញ្ហាណាមួយដែលមិនទាន់ច្បាស់តាមទូរស័ព្ទ
- សួរឈ្មោះរបស់គេ អាយុ  អាស័យដ្ឋាន និងទូរស័ព្ទ មកពីណា?
- បើសិនជាបុគ្គល និងអ្នកមិនអាចពិភាក្សាតាមទូរស័ព្ទបានអោយគាត់មកជួបនៅកន្លែងពិគ្រោះជំងឺ

# ការប៉ាន់ប្រមាណបុគ្គលម្នាក់ដែលមានគ្រួសារនៅក្បែរ

- ក្រុមគ្រួសារគឺជាកត្តាសំខាន់ក្នុងការប៉ាន់ប្រមាណនិងព្យាបាលជំងឺផ្លូវចិត្ត
- អ្នកគួរថ្លឹងថ្លែងវត្តមានគ្រួសារក្នុងការប៉ាន់ប្រមាណ
- ជាគោលការណ៍ត្រូវនិយាយជាមួយអ្នកជំងឺអោយបានយ៉ាងតិចម្តងដង

# ការប៉ាន់ប្រមាណបុគ្គលដែលមានគ្រួសារនៅក្បែរ (ត)

- ក្នុងការសំភាសន៍ជាមួយអ្នកជំងឺអ្នកនឹងបានដឹងពីទំនាក់ទំនងក្នុងគ្រួសារ និងភាពតានតឹងផ្លូវចិត្តដែលអាចកើតមាន
- អ្នកត្រូវមានការប្រុងប្រយ័ត្ន ដោយមិនត្រូវពិភាក្សាបញ្ហាណាមួយដែលអ្នកជំងឺស្នើអោយរក្សាការសំងាត់

# ការប៉ាន់ប្រមាណបុគ្គលដែលមានគ្រួសារនៅក្បែរ (ត)

- ក្នុងករណីអ្នកជំងឺមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរឬមានបញ្ហាគ្រឿងញៀន បងប្អូនអាចជាអ្នកផ្តល់ព័ត៌មានចាំបាច់សម្រាប់ ជួយដល់ការធ្វើរោគវិនិច្ឆ័យ
- បងប្អូនអ្នកជំងឺក៏អាចតាមដានស្ថានភាពសុខភាព និងលើកទឹកចិត្តអ្នកជំងឺក្នុងការប្រើថ្នាំដែលគ្រូពេទ្យផ្តល់អោយ



# ឯកសារសំអាង Reference

ទីណាគ្មានវេជ្ជបណ្ឌិត ឯកទេសវិកលវិទ្យា ទំព័រ ៣៣-៤៤

Where there is no Psychiatrist.

Page 33-44 by Vigram Patel.

Pictures used in this unit taken from differences sources (WHO, FB...)